**វត្តខេមរារង្សីសាជីវកម្មអេស៊ីធី**

**Khemararangsi Buddhist Temple of ACT Inc,**

# បុណ្យវិសាខបូជា និង បុណ្យផ្កាប្រាក់

*អាត្មាភាព យើងខ្ញុំព្រះករុណាទាំងអស់គ្នា ជាគណៈកម្មការចំណុះជើង* **វត្តខេមរារង្សី** *បានមូលមតិគ្នានឹងប្រារព្ធធ្វើបុណ្យវិសាខបូជានិងបុណ្យផ្កាប្រាក់មួយ ព្រោះថាបុណ្យវិសាខបូជានេះគឺមានសារៈសំខាន់ណាស់ក្នុងព្រះពុទ្ធសាសនា ដើម្បីរឭកដល់ព្រះពុទ្ធ* **ទ្រង់ប្រសូត្រ ត្រាស់ដឹង បរិនិព្វាន** *និងប្រមូលបច្ច័យសម្រាប់ទ្រទ្រង់វត្តបន្ថែមទៀត។ព្រោះយើង ចង់បានបច្ច័យខ្លះៗដើម្បីអោយរដ្ឋាភិបាលឃើញនិងចាប់អារម្មណ៍ទៅលើសកម្មភាពភាព ជាបន្តបន្ទាប់របស់ខ្មែរយើងប្រចាំ* **Canberra** *នេះ។ ហើយម្យ៉ាងទៀត យើងនឹងដឹង ដំណឹងពិតប្រាកដថា "តើយើងបានសម្រេច ឬមិនសម្រេចនៅ ថ្ងៃទី ១១ ខែ ០៦ ឆ្នាំ២០១៣ ខាងមុខចាប់ៗនេះ"។*

*អាស្រ័យហេតុ ដូចបានជំរាបជូនខាងលើ សូមពុទ្ធបរិស័ទមេត្តាចូលរួមឲ្យបាន អធិកអធម ដើម្បីទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន អាយុយឺយូរ ដែលកើតចេញអំពីអានិសង្សនៃបុណ្យខាងលើងទាំងពីរនេះ។*

## កម្មវិធីបុណ្យ

*ថ្ងៃសុក្រ ១៥កើត ខែពិសាខ បញ្ចស័ក ព.ស ២៥៥៧ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣។* ***វេលាម៉ោង: ៧:00 P.M*** *ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយនមស្សការ សមាទានសីល ចម្រើនព្រះបរិត្ត សម្តែងព្រះធម៌ទេសនា ស្វូតបទបប្បវត្ត បូជាផ្កា និង ដង្ហែប្រទក្សិណ ៣ជុំចំពោះពុទ្ធអង្គ។ លុះព្រឹកឡើង ថ្ងៃសៅរ៍ ១ រោច ត្រូវនឹងថ្ងៃទី២៥ ខែឆ្នាំដដែល។* ***វេលាម៉ោង: ៩:00-១២:00 A.M*** *បង្សុកូលដាក់បាត្រ និង វេរចង្ហាន់ប្រគេន ព្រះសង្ឃជាកិច្ចបង្ហើយបុណ្យ។ បន្ទាប់មក ពុទ្ធបរិស័ទជួបជុំគ្នាពិសាភោជនាហារថ្ងៃត្រង់ ជាកិច្ចបង្ហើយបុណ្យ។*

***សូមបញ្ជាក់:*** *ពេលល្ងាចថ្ងៃសុក្រ សូមពុទ្ធបរិស័ទ មេត្តាកាន់យកនូវគ្រឿង សក្ការៈបូជាទាំងឡាយមានផ្កាភ្ញី គ្រឿងក្រអូប ដើម្បីបូជាព្រះរតនត្រ័យ។ ពេលព្រឹកថ្ងៃសៅរ៍ មេត្តាកាន់យកនូវចង្ហាន់មកដាក់បាត្រ បង្សុកូល វេរប្រគេនព្រះសង្ឃ និង ទទួលទាននាពេលថ្ងៃត្រង់ផង។*

---

**Please contact: 04 1058 3429/04 7071 1077**